នស/រកត/០៦០២/១៥២

# ព្រះរាជក្រឹត្យ

## ស្តីពី

## លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមន្ទីរ

### យើង

### ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

### រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

### និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

### ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្ស មូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលស្នើសុំពីសម្តេចនាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ កាថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០២ ។

## ត្រាស់បង្គាប់
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើតក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ដែលត្រូវចាត់ថ្នាក់ក្នុងប្រភេទ ខ ដូចមានចែងក្នុងមាត្រា ៤ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ។

**មាត្រា ២.-**

ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ប្រមូលផ្តុំមន្ត្រីបច្ចេកទេសកិរិតមធ្យម បំរើការងារបច្ចេកទេសតាមជំនាញផ្សេងៗ នៅក្នុងក្រសួង ស្ថាប័នរដ្ឋ ។

**មាត្រា ៣.-**

ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួង ស្ថាប័នសាមីនីមួយៗ និងក្រោមការគ្រប់គ្រងរួមរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម មានឧបនិស្ស័យសំរាប់ជាជំនួយ ដល់មន្ត្រីបច្ចេកទេសជាន់ខ្ពស់ក្នុងការសំរេច និង អនុវត្តការងារ និងអាចបំពេញមុខតំណែងដឹកនាំកំរិតមធ្យម ក្នុងអង្គភាពបច្ចេកទេសជំនាញនៅថ្នាក់កណ្តាល និងខេត្ត ក្រុង និងតាមគ្រឹះស្ថានសាធារណៈនានា របស់ក្រសួង ស្ថាប័នរដ្ឋ ។

## ជំពូកទី ២
## ឋានន្តរស័ក្តិ និងមុខតំណែង

**មាត្រា ៤.-**

ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យមមាន ៣ ឋានន្តរស័ក្តិ :

- ឋានន្តរស័ក្តិទី ១ ឬ ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសមធ្យម ដើមខ្សែពិសេស មាន ៦ ថ្នាក់
- ឋានន្តរស័ក្តិទី ២ ឬ ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសមធ្យម ដើមខ្សែ មាន ១០ ថ្នាក់
- ឋានន្តរស័ក្តិទី ៣ ឬ ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសមធ្យម មាន ១៤ ថ្នាក់ ។/.

មាត្រា ៥._

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម អាចកាន់មុខតំណែងគ្រប់គ្រង រួមជាមួយនឹងមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅតាមអង្គភាពជំនាញបច្ចេកទេសនានា របស់ក្រសួង ស្ថាប័ននៅថ្នាក់កណ្ដាល និង ខេត្ត ក្រុង ដូចតទៅ :

• ឋានន្តរស័ក្តិទី ១ :
  - ប្រធានការិយាល័យនៅរដ្ឋបាលកណ្ដាល
  - អនុប្រធានមន្ទីរខេត្ត ក្រុង
• ឋានន្តរស័ក្តិទី ២ :
  - អនុប្រធានការិយាល័យនៅរដ្ឋបាលកណ្ដាល
  - ប្រធានការិយាល័យមន្ទីរខេត្ត ក្រុង
• ឋានន្តរស័ក្តិទី ៣ :
  - អនុប្រធានការិយាល័យមន្ទីរខេត្ត ក្រុង
  - ប្រធានការិយាល័យស្រុក ខ័ណ្ឌ

និងមុខតំណែងឯទៀត ដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ក្នុងឋានន្តរស័ក្តិនីមួយៗ ក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ។

## ជំពូកទី ៣
## ការជ្រើសរើស

មាត្រា ៦._

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ត្រូវធ្វើឡើងតាមការប្រលងជ្រើសរើសក្នុងចំណោមបេក្ខជនជានិស្សិត និងជាមន្ត្រីរាជការ ។

ចំនួនមុខតំណែងជ្រើសរើសតាមជំនាញ និងតាមក្រសួង ស្ថាប័ន ត្រូវកំណត់ដោយរាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដោយយោងតាមការស្នើសុំពីក្រសួង ស្ថាប័នសាមី ។

មាត្រា ៧._

ការប្រលងជ្រើសរើសក្នុងចំណោមនិស្សិត ត្រូវបើកចំហចំពោះបេក្ខជន ដែលមានអាយុច្រើនបំផុត ២៥ ឆ្នាំ គិតមកដល់ថ្ងៃប្រលង និងយ៉ាងទាប មានសញ្ញាប័ត្រមធ្យមបច្ចេកទេស ឬសញ្ញាប័ត្រសមមូល ។

លក្ខខណ្ឌក្នុងការប្រលងចូលក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម សំរាប់បេក្ខជនជាមន្ត្រីរាជការ ត្រូវកំណត់យ៉ាងទាបត្រឹមថ្នាក់លេខ ១១ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម និងមានអាយុយ៉ាងច្រើន ៤០ ឆ្នាំ ។ មន្ត្រីរាជការដែលមានសញ្ញាប័ត្រដូចកំណត់ខាងលើមិនតម្រូវលក្ខខណ្ឌក្របខ័ណ្ឌឡើយ ។ ល.ស.

## ជំពូកទី ៤

## ការបណ្តុះបណ្តាលដំបូង កម្មសិក្សាសាកល្បង និងការតាំងស៊ប់

**មាត្រា ៨.–**

បេក្ខជនដែលបានជ្រើសរើសចូលក្របខ័ណ្ឌ តាមរយៈការប្រលងជ្រើសរើសក្នុងចំណោមនិស្សិត និងក្នុងចំណោមមន្ត្រីរាជការ ត្រូវទទួលការបណ្តុះបណ្តាលដំបូងរៀបចំដោយក្រសួង ស្ថាប័នសាមី ហើយមានឋានៈជានិស្សិតមន្ត្រីបច្ចេកទេសមធ្យម ។

ការបណ្តុះបណ្តាលដំបូង អាចប្រព្រឹត្តទៅតាមលក្ខណៈប្រមូលផ្តុំ ឬតាមការកំណត់ណាមួយផ្សេងទៀតរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៩.–**

បន្ទាប់ពីការបណ្តុះបណ្តាលដំបូង និស្សិតមន្ត្រីបច្ចេកទេសមធ្យម ដែលប្រលងជាប់ ត្រូវបានបែងចែកទៅបំរើការនៅតាមអង្គភាពបច្ចេកទេសជំនាញ នៅខេត្ត ក្រុង និងថ្នាក់កណ្តាលរបស់ក្រសួង ស្ថាប័នសាមី ដោយផ្អែកលើលទ្ធផលនៃការបញ្ចប់វគ្គបណ្តុះបណ្តាល និងទៅតាមជំនាញ ដែលបានជ្រើសរើសក្នុងពេលប្រលងចូល ហើយត្រូវបានតែងតាំងជាមន្ត្រីបច្ចេកទេសមធ្យមកម្មសិក្សា ដោយប្រកាសរបស់ប្រធានស្ថាប័នទទួលបន្ទុក ដោយមានទិដ្ឋាការពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

**មាត្រា ១០.–**

មន្ត្រីបច្ចេកទេសមធ្យម ដែលជ្រើសរើសចេញពីនិស្សិត ត្រូវឆ្លងកាត់កម្មសិក្សារយៈពេល ១២ ខែ។ ក្រោយពេលបញ្ចប់កម្មសិក្សាសាកល្បងដោយជោគជ័យ មន្ត្រីទាំងនេះត្រូវតែងតាំងស៊ប់ក្នុងថ្នាក់លេខ ១៤ នៃឋានន្តរស័ក្តិទី៣ ។

មន្ត្រីបច្ចេកទេសមធ្យម ដែលជ្រើសរើសចេញពីមន្ត្រីបច្ចេកទេសបឋម ពុំចាំបាច់ធ្វើកម្មសិក្សាសាកល្បងទេឡើយ ។ ក្រោយពីបានទទួលការបណ្តុះបណ្តាលដំបូង មន្ត្រីទាំងនេះត្រូវតាំងស៊ប់ក្នុងឋានន្តរស័ក្តិទី ៣ ក្នុងថ្នាក់ដែលមានសន្ទស្សន៍បៀវត្សខ្ពស់បន្ទាប់ពីសន្ទស្សន៍បៀវត្សចាស់របស់មន្ត្រីសាមី ។

ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិទី ៣ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យមត្រូវសំរេចដោយអនុក្រឹត្យ ។

**មាត្រា ១១.–**

មន្ត្រីបច្ចេកទេសមធ្យម ដែលធ្វើកម្មសិក្សាធ្លាក់ក្នុងពេលបំរើការងារ ត្រូវបានអនុញ្ញាតអោយបន្តធ្វើកម្មសិក្សានៅឆ្នាំទី២ទៀត ។ក្នុងករណីធ្លាក់នៅឆ្នាំទី២ នេះ កម្មសិក្សាការីដែលជ្រើសរើសពីនិស្សិត ត្រូវលុបឈ្មោះចេញ ។/.

## ជំពូកទី ៥
## ការតែងតាំង

**មាត្រា ១២.–**

ក្រោយពេលតាំងស៊ប់ក្នុងក្របខ័ណ្ឌ មន្ត្រីបច្ចេកទេសមធ្យមអាចត្រូវបានតែងតាំងក្នុងមុខតំណែងទំនេរណាមួយ ដែលមានកំណត់ក្នុងមាត្រា ៣ និង មាត្រា៥ ខាងលើស្របតាមឋានន្តរស័ក្តិរបស់ខ្លួន តាមបែបបទ ដូចមានកំណត់ក្នុងមាត្រា ២៨ នៃព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។

## ជំពូកទី ៦
## ការដាក់អោយស្ថិតនៅក្រៅក្របខ័ណ្ឌដើម

**មាត្រា ១៣.–**

មន្ត្រីបច្ចេកទេសមធ្យមអាចត្រូវដាក់អោយស្ថិតនៅក្រៅក្របខ័ណ្ឌដើម ឬក្រៅតំណែង ដើម្បីទៅបំរើការនៅក្រសួងស្ថាប័ន ឬអង្គភាពណាមួយផ្សេង តាមតំរូវការ និងតាមការយល់ព្រមពីសាមីខ្លួន ។

## ជំពូកទី ៧
## ការដំឡើងថ្នាក់ និងដំឡើងឋានន្តរស័ក្តិ

**មាត្រា ១៤.–**

មន្ត្រីបច្ចេកទេសមធ្យម ត្រូវបានដំឡើងថ្នាក់ក្នុងឋានន្តរស័ក្តិណាមួយ ទៅតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ២០ និងមាត្រាបន្តបន្ទាប់ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។

លក្ខណៈសម្បត្តិជាមូលដ្ឋាន សំរាប់ការពិនិត្យដំឡើងថ្នាក់ មានដូចខាងក្រោម :

- វិន័យ និងលទ្ធផលនៃការងារ
- ស្មារតីទទួលខុសត្រូវក្នុងការងារ និងមនសិការវិជ្ជាជីវៈ
- សាមគ្គីធម៌ និងសីលធម៌រស់នៅល្អ ។

ការដំឡើងថ្នាក់មន្ត្រីរាជការ ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ ៤ តាមវេនជ្រើសរើស និង១ ភាគ ៤ តាមវេនអតីតភាព ។

ការដំឡើងថ្នាក់ត្រូវសំរេចដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី ។ល។

**មាត្រា ១៥.-**

គោលការណ៍នៃការដំឡើងឋានន្តរស័ក្តិ តាមធម្មតា ត្រូវដំឡើងទៅក្នុងថ្នាក់ដំបូង នៃឋានន្តរស័ក្តិខ្ពស់ លើបន្ទាប់ ឬក្នុងករណីចាំបាច់ ត្រូវដំឡើងទៅក្នុងថ្នាក់ ដែលមានសន្ទស្សន៍ខ្ពស់ បន្ទាប់ពីសន្ទស្សន៍ចាស់ របស់មន្ត្រីសាមី ។

ចំនួនមុខតំណែងក្នុងឋានន្តរស័ក្តិនីមួយៗ ត្រូវកំណត់ដូចតទៅ :

- ៥ % ជាអតិបរមាសំរាប់ឋានន្តរស័ក្តិទី១
- ២៥% ជាអតិបរមាសំរាប់ឋានន្តរស័ក្តិទី២
- ៧០ % ឡើងទៅសំរាប់ឋានន្តរស័ក្តិទី ៣ ។

ការដំឡើងឋានន្តរស័ក្តិត្រូវធ្វើតាមរយៈការចុះឈ្មោះ ក្នុងតារាងតំលើងឋានន្តរស័ក្តិ និងតាមការវាយតំលៃរបស់ឋានានុក្រមគ្រប់គ្រង ឬ តាមរយៈការបណ្តុះបណ្តាល រយៈពេលវែងក្នុង ឬ ក្រៅប្រទេស ។

ការដំឡើងឋានន្តរស័ក្តិ ត្រូវសំរេចដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី ។

**មាត្រា ១៦.-**

អាចដំឡើងទៅក្នុងឋានន្តរស័ក្តិទី២ គឺមន្ត្រីដែលបានឡើងដល់ថ្នាក់លេខ ១១ នៃឋានន្តរស័ក្តិទី៣ ។

អាចដំឡើងទៅក្នុងឋានន្តរស័ក្តិទី ១ គឺមន្ត្រីដែលបានឡើងដល់ថ្នាក់ទី ៧ នៃឋានន្តរស័ក្តិទី ២ ។

**មាត្រា ១៧.-**

សន្ទស្សន៍សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌនិងតម្លៃឯកតានៃសន្ទស្សន៍ ត្រូវកំណត់ស្របតាមមាត្រា ៣ និងមាត្រា ៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការ ។

## ជំពូកទី ៨
## បនប្បញ្ញត្តិដោយឡែក

**មាត្រា ១៨.-**

មន្ត្រីបច្ចេកទេសមធ្យមត្រូវដាក់អោយចូលនិវត្តន៍ ពេលដល់អាយុ ៥៨ ឆ្នាំ ។

ការដាក់អោយចូលនិវត្តន៍ ត្រូវសំរេចដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី ។ ល.ស.

**មាត្រា ១៩.-**

មន្ត្រីរាជការនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ដែលក្រសួង ស្ថាប័ន ចាត់អោយទៅទទួលការបំប៉ន ឬ ការបណ្តុះបណ្តាលជំនាញបន្ត ដែលមានរយៈពេលសរុបចាប់ពី ០១ ឆ្នាំ ឡើងទៅដោយមានវិញ្ញាបនប័ត្របញ្ជាក់ការសិក្សា ត្រូវបានទទួលការដំឡើងថ្នាក់ ០១ ថ្នាក់ ជាស្វ័យប្រវត្តិតាមវេនជ្រើសរើស ។

មន្ត្រីដែលមានសញ្ញាប័ត្រខ្ពស់ជាងសញ្ញាប័ត្រមធ្យមបច្ចេកទេស ត្រូវបានដំឡើងថ្នាក់ ០១ ថ្នាក់ជាស្វ័យប្រវត្តិ ។

**មាត្រា ២០.-**

មន្ត្រីបច្ចេកទេសមធ្យម ត្រូវបានទទួលប្រាក់បំណាច់មុខងារ ប្រាក់ហានិភ័យ និងប្រាក់បំណាច់ផ្សេងៗស្របតាមការកំណត់នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់ បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ ។

**មាត្រា ២១.-**

សញ្ញាស័ក្តិ និងឯកសណ្ឋានសំរាប់មន្ត្រីបច្ចេកទេសមធ្យម ត្រូវកំណត់ដោយព្រះរាជក្រឹត្យមួយដោយឡែក ។

## ជំពូកទី ៩
## អន្តរប្បញ្ញត្តិ

**មាត្រា ២២.-**

ចំនួនដំបូងនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ត្រូវកសាងចេញពីការធ្វើសមាហរណកម្មមន្ត្រីរាជការ ដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌ តាមជំនាញផ្សេងៗ នៅតាមអង្គភាពបច្ចេកទេសជំនាញ ថ្នាក់កណ្តាល និងខេត្ត ក្រុងរបស់ក្រសួង ស្ថាប័ន។

## ជំពូកទី ១០
## អវសានប្បញ្ញត្តិ

**មាត្រា ២៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៤.-**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យ នេះ ។ល៕

**មាត្រា ២៥.-**

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។ ៚.

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ,ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ ២០០២

ព្រះហស្ថលេខា និង ព្រះរាជលញ្ឆករ

នស/រកត/០៦០២/១៦២ នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រសូមឡាយព្រះហស្ថលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

លេខ: ១៣៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០០២

អគ្គលេខាធិការរដ្ឋាភិបាល

ឈាវ តាន់